# ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


២៥-៧-២០០០ -ព្រះរាជក្រម នស/រកម/០៧០០/០២ច្បាប់ស្តីពីការធានារ៉ាប់រង ១២៤៧

២៥-៧-២០០០ -ព្រះរាជក្រម នស/រកម/០៧០០/០៣ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពិធីសារ និង អនុស្សរណៈ នៃសមគមប្រជាជាតិអាស៊ីអាគ្នេយ៍ លោកកាត់ផា អាស៊ាន ១២៦០

២៥-៧-២០០០ -ព្រះរាជក្រម នស/រកម/០៧០០/០៤ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ១២៦៣

៣០-៧-២០០០ -ព្រះរាជក្រម នស/រកម/០៧០០/០៥ ច្បាប់ស្តីពីការការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ១២៦៥

៣០-៧-២០០០ -ព្រះរាជក្រម នស/រកម/០៧០០/០៦ ច្បាប់ស្តីពីការការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ១២៦៦

៣០-៧-២០០០ -ព្រះរាជក្រម នស/រកម/០៧០០/០៧ ច្បាប់ស្តីពីការទូទាត់ថវិការទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ១២៦


### ២-ព្រះរាជក្រឹត្យ


២៥-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកម/០៧០០/១៣៥ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ១២៧

២៧-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកម/០៧០០/១៣៦ តែងតាំងឯកឧត្តម ជាខ អេខខួន ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌាបង់ក្លាដេសម៉ូរីស ស្រីលង្កា និង ស៊ីហ្សែល ១២៨

៣០-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកម/០៧០០/១៣៧ តែងតាំងលោក ឆេខ ឃីហេខ ជាអ៊ុកញ៉ា ១២៨១

៣០-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកម/០៧០០/១៣៨ តែងតាំងឯកឧត្តម អ៊ុក សារ៉ាឲុធ ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី ១ រដ្ឋសភា ១២៨១
៣០-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកម/០៧០០/១៣៩ តម្លើងឋានៈឯកឧត្តម គាំម កុសល បច្ចុប្បន្នជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី ១ រដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១២៨២
៣០-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកម/០៧០០/១៤០ តម្លើងឋានៈឯកឧត្តម ម៉ុ ខេន បច្ចុប្បន្ន ជាទីប្រឹក្សាសម្តេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ១២៨៣
៣១-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៤១ តែងតាំងលោក **លឹម ហ៊ុយឡេង** ជាឧកញ៉ា ១២៨៤
៣១-៧-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៤២ តែងតាំងផ្លាស់ប្តូរមុខងារ និងតម្លើងឋានន្តរសក្តិ ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទ ១២៨៤


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៥-៧-២០០០ -អនុក្រឹត្យលេខ ៤៥ អនក្រ .បក ស្តីពីការបង្កើតមហាវិទ្យាល័យ គ្រប់គ្រង និង នីតិសាស្ត្រ ១២៨៦
២៥-៧-២០០០ -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្តីពីការកែប្រែរចនាសម្ព័ន្ធនៃមហាវិទ្យាល័យនរោត្តម ទៅជា សាកលវិទ្យាល័យនរោត្តម ១២៨៨
២៧-៧-២០០០ -អនុក្រឹត្យលេខ ៤៧ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ១២៩១
២៧-៧-២០០០ -អនុក្រឹត្យលេខ ៤៨ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ១២៩២
៣១-៧-២០០០ -អនុក្រឹត្យលេខ ៤៩ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ១២៩៣
២៥-៧-២០០០ -អនុក្រឹត្យលេខ ២៧០ អនក្រ .គត ស្តីពីការជូនមេដាយការងារ ១២៩៥
២៥-៧-២០០០ -អនុក្រឹត្យលេខ ២៧១ អនក្រ .គត ស្តីពីការជូនមេដាយការងារ ១២៩៦
២៦-៧-២០០០ -អនុក្រឹត្យលេខ ២៧២ អនក្រ .គត ស្តីពីការជូនមេដាយការងារ ១២៩៨
២៦-៧-២០០០ -អនុក្រឹត្យលេខ ២៧៣ អនក្រ .គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៩៩
២៦-៧-២០០០ -អនុក្រឹត្យលេខ ២៧៤ អនក្រ .គត ស្តីពីការជូនមេដាយការងារ ១៣០០
២៦-៧-២០០០ -អនុក្រឹត្យលេខ ២៧៥ អនក្រ .គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣០១
២៦-៧-២០០០ -អនុក្រឹត្យលេខ ២៧៦ អនក្រ .គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣០២

# គ


| | | |
|---|---|---|
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៧៧ អនក្រ .តត ស្តីពីការផ្តល់ងារជាតិ ស្ថាបនាជាតិ | ១៣០៣ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៧៨ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣០៤ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៧៩ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣០៥ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨០ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣០៦ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨១ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣០៦ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨២ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣០៧ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨៣ អនក្រ .តត ស្តីពីការជូនមេដាយការងារ | ១៣០៨ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨៤ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣០៩ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨៥ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៣១០ |
| ២៦-៧-២០០០ | -អនុក្រឹត្យលេខ ២៨៦ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣១១ |
| ៣១-៧-២០០០ | -អនុក្រឹត្យលេខ ២៨៧ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៣១២ |
| ៣១-៧-២០០០ | -អនុក្រឹត្យលេខ ២៨៨ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៣១៣ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ២៥-៧-២០០០ | -សេចក្តីសំរេចលេខ ៤៩ សសរ. ស្តីពីការបង្កើតគណៈកម្មការជាតិពិភាក្សា ផ្តល់យោបល់ និង ដោះស្រាយបាតុភាពលើការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ | ១៣១៤ |

# I- ព្រះរាជក្រម

## ព្រះរាជក្រម នស/រកម/០៧០០/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការធានារ៉ាប់រង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# ការធានារ៉ាប់រង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងកិច្ចប្រតិបត្តិការធានារ៉ាប់រងការពារសិទ្ធិត្រឹមត្រូវរបស់ភាគីនានាចំពោះការធានារ៉ាប់រង ពង្រឹងការត្រួតពិនិត្យនិងគ្រប់គ្រងអាជីវកម្មធានារ៉ាប់រង និង រួមចំណែកដល់កិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រង ។

មាត្រា ២.-

ច្បាប់នេះអនុវត្តចំពោះសកម្មភាពធានារ៉ាប់រងទាំងអស់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ការធានារ៉ាប់រងដែលប្រើនៅក្នុងច្បាប់នេះ គឺសំដៅលើការធ្វើកិច្ចសន្យាពាណិជ្ជកម្មធានារ៉ាប់រងមួយ ដែលក្នុងនោះអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភរ៉ាប់រងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធើសំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺឬក៏នៅពេលដែលបុគ្គលនោះឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

មាត្រា ៤.-

អាចប្រកបអាជីវកម្មធានារ៉ាប់រងបាន គឺក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ។

មាត្រា ៥.-

ក្នុងកិច្ចប្រតិបត្តិការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ត្រូវគោរពតាមគោលការណ៍ប្រកួតប្រជែងត្រឹមត្រូវដោយ អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៦.-

រូបវន្តបុគ្គលនិងនីតិបុគ្គលដែលទទួលអាណាព្យាបាលធ្វើសកម្មភាពធានារ៉ាប់រង ត្រូវគោរពបទប្បញ្ញត្តិនិងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៧.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវគ្រប់គ្រងនិងត្រួតពិនិត្យលើអាជីវកម្មធានារ៉ាប់រងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ២

## កិច្ចសន្យាធានារ៉ាប់រង

### ផ្នែកទី ១

### មែបទទូទៅ

មាត្រា ៨.-

ការធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកត្រូវបានធានារ៉ាប់រងចំពោះហានិភ័យទាំងឡាយ ទោះជាអាយុជីវិត ឬមិនមែនអាយុជីវិតត្រូវចុះកិច្ចសន្យាធានារ៉ាប់រងតែជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណឲ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩.-

កិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ គឺជាការព្រមព្រៀងមួយដែលចែងអំពីទំនាក់ទំនងរវាងសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង និងអ្នកធានារ៉ាប់រង ។

អ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដែលចុះកិច្ចសន្យាជាមួយអ្នកធានារ៉ាប់រងហើយមានកាតព្វកិច្ចបង់បុព្វលាភរ៉ាប់រង ។

អ្នកធានារ៉ាប់រងគឺជាក្រុមហ៊ុនធានារ៉ាប់រងដែលចុះកិច្ចសន្យាជាមួយអ្នកត្រូវបានធានារ៉ាប់រងហើយមានកាតព្វកិច្ចធ្វើសំណងទាំងឡាយ និង/ឬបង់នូវផលប្រយោជន៍ទាំងឡាយ ។

មាត្រា ១០.-

ក្នុងការធ្វើកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ត្រូវគោរពតាមគោលការណ៍ស្មោះត្រង់មានផលប្រយោជន៍ទៅវិញទៅមកមានការស្រុះស្រួលគ្នាដោយស្ម័គ្រចិត្តតាមការចរចានិងមិនធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈឡើយ ។

មាត្រា ១១.-

ក្នុងការអនុវត្តន៍កិច្ចសន្យាធានារ៉ាប់រង ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ដោយការជូនដំណឹងជាមុនតាមរយៈលិខិតអនុសិដ្ឋ ឬតាមរយៈលិខិតជូនដំណឹងដែលមានបញ្ជាក់ការទទួលច្បាស់លាស់ ។

មាត្រា ១២.-

នៅពេលដែលរូបវ័ន្តបុគ្គលឬនីតិបុគ្គលធ្វើសំណើសុំការធានារ៉ាប់រងហើយ ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមទទួលសំណើព្រមទាំងបានឯកភាពលើលក្ខខ័ណ្ឌផ្សេងៗ នៃកិច្ចសន្យាហើយនោះ កិច្ចសន្យាធានារ៉ាប់រងអាចចាត់ទុកថាបានព្រមព្រៀងគ្នារួចហើយ ។ បន្ទាប់មក ក្រុមហ៊ុនធានារ៉ាប់រងត្រូវចេញប័ណ្ណសន្យារ៉ាប់រងដែលភ្ជាប់នឹងវិញ្ញាបនប័ត្រធានារ៉ាប់រងទៅឲ្យអ្នកស្នើសុំធានារ៉ាប់រង ។ ប័ណ្ណសន្យារ៉ាប់រងដែលភ្ជាប់នឹងវិញ្ញាបនប័ត្រធានារ៉ាប់រងត្រូវមានចែង និងកំណត់ខ្លឹមសារសំខាន់ជាមូលដ្ឋានដែលបានព្រមព្រៀងជាមុនរវាងភាគីទាំងពីរ ។

មាត្រា ១៣.-

វិញ្ញាបនប័ត្រធានារ៉ាប់រងត្រូវបានបញ្ជាក់ :

១- គោត្តនាមនិងនាមនិងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
២- បុគ្គលឬវត្ថុត្រូវបានធានារ៉ាប់រង
៣- ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង
៤- ពេលវេលាចាប់ផ្តើមនិងទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង
៥- ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង
៦- បុព្វលាភរ៉ាប់រងត្រូវបង់និងរបៀបបង់បុព្វលាភរ៉ាប់រង
៧- របៀបនិងលក្ខខ័ណ្ឌមួយចំនួននៃសេចក្តីប្រកាសគ្រោះថ្នាក់
៨- រយៈពេលនៃកិច្ចសន្យានិងរយៈពេលនៃការធានារ៉ាប់រង
៩- លក្ខខ័ណ្ឌទាំងឡាយដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងលក្ខខ័ណ្ឌដែលអនុញ្ញាតដល់ភាគីនីមួយៗបញ្ឈប់កិច្ចសន្យាបានមុនកាលកំណត់ ។

មាត្រា ១៤.-

មានតែប័ណ្ណសន្យារ៉ាប់រង ឬកំណត់សំអាងទេដែលកត់ត្រាការធានាទៅវិញទៅមក រវាងក្រុមហ៊ុនធានារ៉ាប់រងនិងអ្នកត្រូវបានធានារ៉ាប់រង ។ រីឯពាក្យស្នើសុំធានារ៉ាប់រងមិនមានតំលៃធានាដល់ភាគីទាំងពីរទេ ។

សំណើសុំបន្ត កែប្រែឬដាក់ឲ្យចូលជាធរមានឡើងវិញនូវកិច្ចសន្យាធានារ៉ាប់រងមួយដែលបានព្យួរទុកត្រូវបានចាត់ថាយល់ព្រម ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមិនបដិសេធនូវសំណើនោះក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ។

មាត្រា ១៥.-

រយៈពេលនៃកិច្ចសន្យាធានារ៉ាប់រងមានកំណត់នៅក្នុងប័ណ្ណសន្យារ៉ាប់រង ។ រាល់ការបន្ថែមឬកែប្រែលើប័ណ្ណសន្យាដើមត្រូវធ្វើឡើងដោយកិច្ចសន្យាបន្ថែម និងត្រូវមានចុះហត្ថលេខារបស់ភាគីទាំងសងខាង ។

មាត្រា ១៦.-

អ្នកត្រូវបានធានារ៉ាប់រងត្រូវមានផលប្រយោជន៍ពីការធានារ៉ាប់រងដែលស្ថិតក្នុងកម្មវត្ថុត្រូវបានធានារ៉ាប់រង ។

ផលប្រយោជន៍ពីការធានារ៉ាប់រងមានន័យថា អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិក្នុងការទទួលយកផលប្រយោជន៍ដែលស្ថិតក្នុងកម្មវត្ថុត្រូវបានធានារ៉ាប់រង ។

កម្មវត្ថុត្រូវបានធានារ៉ាប់រងមានន័យថា ទ្រព្យសម្បត្តិផលឬប្រយោជន៍អ្វីមួយដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ អាយុជីវិតឬរូបរាងកាយរបស់ជនណាមួយ ។

មាត្រា ១៧.-

បន្ទាប់ពីបានធ្វើកិច្ចសន្យាធានារ៉ាប់រងរួចហើយ អ្នកត្រូវធានារ៉ាប់រងត្រូវបង់បុព្វលាភរ៉ាប់រងដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

ការធានារ៉ាប់រងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលអ្នកត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភរ៉ាប់រងតាមការកំណត់ក្នុងកិច្ចសន្យា ។

មាត្រា ១៨.-

ក្នុងករណីដែលពុំបានបង់បុព្វលាភរ៉ាប់រងណាមួយតាមកាលកំណត់នោះសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងមិនអាចព្យួរទុកឲ្យហួសពីរយៈពេល៣០ (សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចសន្យាធានារ៉ាប់រងឡើយ ។ ២០ (ម្ភៃ) ថ្ងៃក្រោយពីការចុះកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងដោយលិខិតអនុសិដ្ឋ ឬដោយលិខិតដែលមានបញ្ជាក់ការទទួលច្បាស់លាស់ដល់អ្នកត្រូវបានធានារ៉ាប់រងឬជនដែលមានភារកិច្ចបង់បុព្វលាភរ៉ាប់រងឲ្យយកបុព្វលាភរ៉ាប់រងមកបង់នៅទីកន្លែងដែលបានព្រមព្រៀងគ្នា ។ ក្រោយពីបានទទួលដំណឹងរួចហើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅតែមិនមកបង់បុព្វលាភរ៉ាប់រងក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នោះក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិលុបកិច្ចសន្យាចោល ។

មាត្រា ១៩.-

ការបាត់បង់ឬការខូចខាតទាំងឡាយបណ្តាលមកពីហានិភ័យដែលមានចែងក្នុងប័ណ្ណសន្យារ៉ាប់រងត្រូវស្ថិតនៅក្នុងបន្ទុកធ្វើសំណងរបស់ក្រុមហ៊ុនធានារ៉ាប់រង ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនធ្វើសំណងចំពោះការបាត់បង់ ឬការខូចខាតទាំងឡាយដែលបណ្តាលមកពីកំហុសដោយចេតនា ឬដោយបន្លំបោកប្រាស់របស់អ្នកត្រូវបានធានារ៉ាប់រងឡើយ ។

ក្រុមហ៊ុនធានារ៉ាប់រងធានាផងដែរចំពោះការបាត់បង់និងការខូចខាតបង្កឡើងដោយបុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រងទោះជាប្រភេទនិងភាពធ្ងន់ធ្ងរនៃកំហុសទាំងនោះបែបណាក៏ដោយ ។

**មាត្រា ២០.-**

កិច្ចសន្យាធានារ៉ាប់រងមួយចាត់ទុកជាមោឃៈ នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញថា អ្នកត្រូវបានធានារ៉ាប់រងមានការលាក់លៀម ឬធ្វើប្រតិវេទន៍ខុសដោយចេតនាហើយបណ្តាលឲ្យមានការប្តូរកម្មវត្ថុនៃហានិភ័យ ។

ការភ្លេចភ្លាំង ឬការធ្វើប្រតិវេទន៍មិនច្បាស់លាស់របស់អ្នកត្រូវបានធានារ៉ាប់រងដោយចេតនានឹងមិននាំទៅដល់ មោឃភាពនៃការធានារ៉ាប់រង ។

**មាត្រា ២១.-**

ប្រសិនបើគ្រោះភ័យបានកើតឡើងដោយអំពើចេតនារបស់អ្នកត្រូវបានធានារ៉ាប់រង នោះ មិនក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយក្តី ឬមិនទាន់បានធ្វើសំណងក្តី ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញនូវអំពើតបន្លំ ឬការប្រឌិតនូវគ្រោះថ្នាក់ដោយអាស្រ័យភស្តុតាងច្បាស់លាស់នោះ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំបដិសេធការទទួលខុសត្រូវឬទារសំណងមកវិញ ។

**មាត្រា ២២.-**

រាល់ព័ត៌មានទាក់ទងនឹងសិទ្ធិណាមួយរបស់អ្នកត្រូវបានធានារ៉ាប់រងដែលមានចែងក្នុងលក្ខខណ្ឌទូទៅនៃប័ណ្ណសន្យារ៉ាប់រង នឹងត្រូវចាត់ទុកជាមោឃៈនៅពេលដែលមានភស្តុតាងបញ្ជាក់ថា អ្នកត្រូវបានធានារ៉ាប់រងមានកំហុសហើយសាមីខ្លួនទទួលស្គាល់ ។

**មាត្រា ២៣.-**

ក្នុងប្រភេទធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានបង្កឲ្យមានការខូចខាតឬបាត់បង់ដល់តតិយជន ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងផ្ទាល់ទៅតតិយជនដែលរងគ្រោះនោះ ។

ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវគឺជាការធានារ៉ាប់រងមួយប្រភេទដែលក្នុងនោះការធ្វើសំណងផ្នែកភារៈទទួលខុសត្រូវ ត្រូវធ្វើដោយផ្ទាល់ទៅឲ្យតតិយជនដែលជាកម្មវត្ថុនៃការធានារ៉ាប់រង ។

**មាត្រា ២៤.-**

ក្នុងករណីធានារ៉ាប់រងបន្ត ក្រុមហ៊ុនធានារ៉ាប់រងដើមនៅតែទទួលខុសត្រូវតែឯងចំពោះអ្នកត្រូវបានធានារ៉ាប់រង ។

ការធានារ៉ាប់រងបន្តគឺជាកិច្ចប្រតិបត្តិការធានារ៉ាប់រង ដែលក្រុមហ៊ុនធានារ៉ាប់រងដើមត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្តនូវហានិភ័យមួយផ្នែក ឬទាំងស្រុងដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង ។

មាត្រា ២៥.

បណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងកិច្ចធានារ៉ាប់រង ត្រូវមានកំណត់អាជ្ញាយុកាលក្នុងប័ណ្ណសន្យារ៉ាប់រង ។ ប៉ុន្តែអាជ្ញាយុកាលនេះមិនត្រូវលើសពី ៣ (បី) ឆ្នាំ គិតចាប់ពីពេលដែលមានគ្រោះភ័យកើតឡើង ។

អាជ្ញាយុកាលត្រូវបញ្ឈប់ដោយការព្រមព្រៀងគ្នារវាងភាគីទាំងពីរ បន្ទាប់ពីមានការបញ្ជាក់របស់អ្នកត្រួតពិនិត្យដែលជាអាជ្ញាកណ្តាលក្រោយពីគ្រោះភ័យកើតឡើង ។

ផ្នែកទី២

ការធានារ៉ាប់រងទ្រព្យសម្បត្តិ

មាត្រា ២៦.-

ការធានារ៉ាប់រងទ្រព្យសម្បត្តិគឺជាកិច្ចសន្យាធ្វើសំណងមួយនៅពេលដែលមានគ្រោះភ័យកើតឡើង ។

សំណងដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រងទៅឲ្យអ្នកត្រូវបានធានារ៉ាប់រងមិនអាចលើសពីតំលៃនៃវត្ថុបានធ្វើប្រតិវេទន៍នៅពេលចុះកិច្ចសន្យាធានារ៉ាប់រងឡើយ លើកលែងតែមានការព្រមព្រៀងគ្នាដោយឡែក ។

មាត្រា ២៧.-

ករណីមានការបាត់បង់ទាំងស្រុងនូវវត្ថុដែលត្រូវបានធានារ៉ាប់រងបណ្តាលមកពីហេតុការណ៍ណាមួយដែលពុំបានគ្រោងទុកជាមុនក្នុងប័ណ្ណសន្យារ៉ាប់រងទេ ការធានារ៉ាប់រងត្រូវបញ្ចប់ដោយគ្រប់ច្បាប់ ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងទៅអ្នកត្រូវបានធានារ៉ាប់រងវិញចំនួន ៩០(កៅសិប)ភាគរយ នៃបុព្វលាភរ៉ាប់រងចំពោះរយៈពេលដែលនៅសល់ ។

មាត្រា ២៨.-

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្ទេរសិទ្ធិទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងក្នុងការប្តឹងតទល់ជាមួយតតិយជន ដែលបានបង្កឲ្យមានការខូចខាត ដើម្បីទាមទារមកវិញនូវទឹកប្រាក់ស្មើនឹងចំនួនដែលបានធ្វើសំណងនោះ ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្តឹងសើរើនឹងបច្ចាញាតិ បុព្វជន ញាតិព័ន្ធ អ្នកគ្រប់គ្រងនិងនិយោជិតដែលរស់នៅធម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងទេ លើកលែងតែក្នុងករណីល្មើសបទប្រព្រឹត្តដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះ ។

ផ្នែកទី ៣

ការធានារ៉ាប់រងបុគ្គល

មាត្រា ២៩.-

ក្នុងការធានារ៉ាប់រងបុគ្គល ចំនួនទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់ក្នុងប័ណ្ណសន្យារ៉ាប់រងគឺជាកំរិតខ្ពស់បំផុតនៃចំនួនទឹកប្រាក់ដែលត្រូវសង ។

ការធានារ៉ាប់រងបុគ្គលរួមមានការធានារ៉ាប់រងលើអាយុជីវិត និងការធានារ៉ាប់រងលើគ្រោះថ្នាក់ទាំងឡាយដល់រូបរាងកាយ ។

**មាត្រា ៣០.-**

ក្នុងការធានារ៉ាប់រងបុគ្គល ក្រោយពីបានធ្វើសំណងរួចហើយ ក្រុមហ៊ុនធានារ៉ាប់រងមិនអាចទាមទារការផ្ទេរសិទ្ធិពីភាគីជាប់កិច្ចសន្យា ឬអ្នកទទួលផលដើម្បីប្តឹងតទល់ជាមួយតតិយជនឡើយ ។

**មាត្រា ៣១.-**

បុគ្គលម្នាក់ៗអាចស្នើសុំការធានារ៉ាប់រងលើអាយុជីវិតរបស់ខ្លួន ឬរបស់តតិយជន កាលបើតតិយជននោះបានយល់ព្រមជាលាយលក្ខណ៍អក្សរបញ្ជាក់ច្បាស់ពីចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង ។

ការធានារ៉ាប់រងលើមរណភាពត្រូវបានហាមឃាត់ចំពោះ :

១- ជនមិនពេញលក្ខណៈខាងសតិ ។

២- ជនដែលកំពុងព្យាបាលនៅក្នុងមន្ទីរពេទ្យវិកលចរិត ។

**មាត្រា ៣២.-**

ក្រៅពីនិទ្ទេសចាំបាច់ក្នុងកិច្ចសន្យាធានារ៉ាប់រង បណ្ណសន្យារ៉ាប់រងលើអាយុជីវិតត្រូវបញ្ជាក់ដូចខាងក្រោមនេះ :

១- គោត្តនាម-នាមនិងថ្ងៃខែឆ្នាំកំណើតរបស់អ្នកដែលត្រូវចុះកិច្ចសន្យា ។

២- គោត្តនាមនិងនាមរបស់អ្នកទទួលផល ប្រសិនបើមាន ។

៣- ហេតុការណ៍ ឬការកំណត់ដែលត្រូវប្រគល់ឲ្យវិញនូវទឹកប្រាក់ធានារ៉ាប់រង ។

៤- ល័ក្ខខ័ណ្ឌនៃការបន្ធូរបន្ថយ បើសិនជាមានចែងនៅក្នុងកិច្ចសន្យា ។

**មាត្រា ៣៣.-**

ការធានារ៉ាប់រងលើមរណភាពត្រូវចាត់ទុកថាគ្មានប្រសិទ្ធិភាព ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងធ្វើអត្តឃាត ។

**មាត្រា ៣៤.-**

កិច្ចសន្យាធានារ៉ាប់រងលែងមានប្រសិទ្ធភាពចំពោះអ្នកទទួលផល នៅពេលដែលអ្នកទទួលផលនោះបានសំលាប់ ឬសមគំនិតសំលាប់អ្នកត្រូវបានធានារ៉ាប់រងដោយចេតនា ។

**មាត្រា ៣៥.-**

វិវាទរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងដែលពុំអាចដោះស្រាយបានដោយការសំរុះសំរួលគ្នា ឬតាមរយៈអាជ្ញាកណ្តាលទេនោះ ភាគីទាំងពីរអាចប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ប្រភេទធានារ៉ាប់រងជាកាតព្វកិច្ច
### ផ្នែកទី ១
### ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន

**មាត្រា ៣៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់យានយន្តដែលប្រកបអាជីកម្មយកកំរៃតាមផ្លូវគោកនានាក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការធានារ៉ាប់រងយានយន្តរបស់ខ្លួនពីក្រុមហ៊ុនធានារ៉ាប់រងណាមួយលើភារៈទទួលខុសត្រូវចំពោះរាល់ការខូចខាតដែលបណ្តាលមកពីសកម្មភាពនៃយានយន្តរបស់ខ្លួន រួមទាំងរ៉ឺម៉កសណ្តោងគ្រប់ប្រភេទបង្កឡើងដល់តតិយជន ។

ការធានារ៉ាប់រងនេះមិនត្រឹមតែមានប្រសិទ្ធភាពចំពោះម្ចាស់យានយន្តប៉ុណ្ណោះទេប៉ុន្តែត្រូវមានប្រសិទ្ធភាពផងដែរចំពោះអ្នកបើកបរនិងអ្នកកាន់កាប់ថែទាំយានយន្ត ។

ប្រភេទយានយន្តប្រកបអាជីកម្មទាំងឡាយដែលត្រូវបានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៧.-**

តតិយជនទាំងឡាយដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់ចរាចរ ហើយបានទទួលរងគ្រោះដល់រូបរាងកាយឬទ្រព្យសម្បត្តិដោយសារយានយន្តប្រកបអាជីកកម្មលើផ្លូវគោកបង្កឡើង សុទ្ធតែត្រូវបានក្រុមហ៊ុនធានារ៉ាប់រងធ្វើសំណងចំពោះរាល់ការខូចខាតអន្តរាយនោះឲ្យទាន់ពេលវេលានិងសមស្របទៅតាមកំរិតនៃការខូចខាត ។

**មាត្រា ៣៨.-**

ការធានារ៉ាប់រងតតិយជនមិនអនុវត្តចំពោះការខូចខាតបណ្តាលមកពីគ្រោះថ្នាក់ដែលកើត ឡើងនៅក្រៅភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែមានកិច្ចព្រមព្រៀងដោយ ឡែក ។

**មាត្រា ៣៩.-**

ការធានារ៉ាប់រងនេះអនុវត្តចំពោះជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរដែលបានទទួលរងរបួស ពិការ ឬមរណភាព ទោះបីជនទាំងនោះត្រូវបានដឹកជញ្ជូនក្នុងយានយន្តដែលត្រូវបានធានារ៉ាប់រងក៏ដោយ ។

### ផ្នែកទី ២
### ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

**មាត្រា ៤០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយដែលជាម្ចាស់ការដ្ឋាន ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ។

នៅពេលបើកការដ្ឋាន បុគ្គលទាំងនោះត្រូវបញ្ជាក់ថា ខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ ។

ប្រភេទការដ្ឋានដែលត្រូវមានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤១.-

កិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ដែលធ្វើឡើងស្របតាមមាត្រា ៤០ នៃច្បាប់នេះត្រូវមានលក្ខខណ្ឌទាំងឡាយស្តីពីការធានារ៉ាប់រងសំរាប់រយៈពេលបន្ទាប់ពីការបញ្ចប់ការដ្ឋាន ។

### ផ្នែកទី ៣
### ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

មាត្រា ៤២.-

រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូនណាមួយ ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវចំពោះអ្នកដំណើរដែលជិះតាមមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន ទោះបីមធ្យោបាយដឹកជញ្ជូនទាំងនោះចរាចរលើផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ឬផ្លូវដែកក៏ដោយ ។

ប្រភេទមធ្យោបាយដឹកជញ្ជូនអ្នកដំណើរដែលត្រូវមានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ក្រុមហ៊ុនធានារ៉ាប់រងនិងការត្រួតពិនិត្យរបស់រដ្ឋ

### ផ្នែកទី ១
### ក្រុមហ៊ុនធានារ៉ាប់រង

មាត្រា ៤៣.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវមានចុះបញ្ជីពាណិជ្ជកម្ម ហើយស្ថិតនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤៤.-

ក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្រគល់អំណាចដឹកនាំ ចាត់ចែង ឬចាត់ឲ្យដល់បុគ្គលទាំងឡាយណាដែលធ្លាប់មានទោសណាមួយដូចជា : បទល្មើសចោរកម្ម បទល្មើសរំលោភសេចក្តីទុកចិត្ត បទល្មើសចេញមូលប្បទានប័ត្រគ្មានសវិធានវត្ថុដោយចេតនា បទល្មើសប៉ះពាល់ផលប្រយោជន៍រដ្ឋ បទល្មើសឆបោក ឬអំពើនៃការលាក់វត្ថុដែលបានមកពីការប្រព្រឹត្តិបទល្មើស ។

រាល់ការផ្តន្ទាទោសដោយការប៉ុនប៉ងឬការសមគំនិតក្នុងការប្រព្រឹត្តិបទល្មើសដូចខាងលើននេះ ឬមួយរាល់ការផ្តន្ទាទោសជាប់ពន្ធនាគារមួយឆ្នាំយ៉ាងតិចទោះបីជាប្រភេទបទល្មើសណាក៏ដោយដែលបានប្រព្រឹត្ត គឺសុទ្ធតែផ្តល់នូវអសមត្ថភាពដូចគ្នា ។

មាត្រា ៤៥.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ទោះជាកម្មសិទ្ធិជារបស់ឯកជនក្តី ឬជាក្រុមហ៊ុនចំរុះក្តី អាចត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា តែក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនភាគហ៊ុនប៉ុណ្ណោះ ។

មាត្រា ៤៦.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយអាចធ្វើប្រតិបត្តិការជ្រើសរើសយកធានារ៉ាប់រងបានតាមប្រភេទជា :

ក- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលត្រូវមានដើមទុនចុះបញ្ជីជាប្រាក់សុទ្ធយ៉ាងតិចបំផុតសមមូលនឹង ៥.០០០.០០០ (ប្រាំលាន) អេសឌីអរ តាមអត្រាពេលចេញអាជ្ញាប័ណ្ណ ។

ខ- ក្រុមហ៊ុនធានារ៉ាប់រងទូទៅដែលត្រូវមានដើមទុនចុះបញ្ជីជាប្រាក់សុទ្ធយ៉ាងតិចបំផុតសមមូលនឹង ៥.០០០.០០០ (ប្រាំលាន) អេសឌីអរ តាមអត្រាពេលចេញអាជ្ញាប័ណ្ណ ។

គ- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនិងទូទៅដែលត្រូវមានដើមទុនចុះបញ្ជីជាប្រាក់សុទ្ធយ៉ាងតិចបំផុតសមមូលនឹង ១០.០០០.០០០ (ដប់លាន) អេសឌីអរ តាមអត្រាពេលចេញអាជ្ញាប័ណ្ណ ។

មាត្រា ៤៧.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់មិនអាចធ្វើអាជីវកម្មនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានទេ បើសិនជាក្រុមហ៊ុននោះ :

ក-មិនមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច

ខ-មិនបានចុះបញ្ជីសំរាប់ប្រភេទណាមួយដូចមានចែងក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

មាត្រា ៤៨.-

មុននឹងចាប់ផ្តើមដំណើរការអាជីវកម្ម ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលមានការអនុញ្ញាតរួចហើយត្រូវបំពេញបែបបទដូចខាងក្រោមនេះនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ :

-ផ្តល់លិខិតឬឯកសារដែលបញ្ជាក់អះអាងថាបានដាក់ប្រាក់តំកល់ចំនួនស្មើនឹង ១០(ដប់) ភាគរយនៃដើមទុននៅធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជារួចហើយ ។ ប្រាក់តំកល់នេះត្រូវបានរក្សាទុករហូតដល់ពេលដែលក្រុមហ៊ុនបញ្ឈប់សកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ។

-ផ្តល់លិខិត ឬឯកសារដែលបញ្ជាក់អះអាងថា បានរក្សាទុកទឹកប្រាក់ជាសុធនភាពនៅធនាគារណាមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិ ។ កំរិតសុធនភាពនេះត្រូវបានកំណត់ទៅតាមប្រភេទក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ។ ប៉ុន្តែកំរិតជាអប្បបរមានៃសាធនភាពមិនទាបជាង ៥០(ហាសិប) ភាគរយនៃដើមទុនចុះបញ្ជីឡើយ ។

## ផ្នែកទី ២
## ការត្រួតពិនិត្យរបស់រដ្ឋ

**មាត្រា ៤៩.-**

ការត្រួតពិនិត្យរបស់រដ្ឋធ្វើឡើងដើម្បីផលប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង អ្នកចុះកិច្ចសន្យា និងអ្នកទទួលផលនៃកិច្ចសន្យាធានារ៉ាប់រង និងដើម្បីផលប្រយោជន៍នៃមូលធនកម្ម ។

ចំពោះក្រុមហ៊ុនរដ្ឋនិងក្រុមហ៊ុនចំរុះដែលមានភាគកម្មយ៉ាងតិច ៥១ (ហាសិបមួយ) ភាគរយជារបស់រដ្ឋ ត្រូវអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

ចំពោះក្រុមហ៊ុនឯកជនត្រូវអនុវត្តតាមអាជ្ញាប័ណ្ណដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## ភ្នាក់ងារធានារ៉ាប់រងនិងជើងសាធានារ៉ាប់រង

**មាត្រា ៥០.-**

ភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលកំរៃពីក្រុមហ៊ុនធានារ៉ាប់រងនិងកាន់កាប់អាជីវកម្មធានារ៉ាប់រង ជួសមុខឲ្យក្រុមហ៊ុនធានារ៉ាប់រងក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ច្បាស់លាស់ ។

ជើងសាធានារ៉ាប់រងជានីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ផ្តល់នូវសេវាជាអ្នកកណ្តាលរវាងអ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដើម្បីសំរេចនូវកិច្ចសន្យាធានារ៉ាប់រងណាមួយ និងប្រមូលកំរៃជើងសាស្របច្បាប់ ។

**មាត្រា ៥១.-**

បែបបទនៃការរៀបចំនិងការប្រព្រឹត្តទៅនៃភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ព្រមទាំងលក្ខខ័ណ្ឌផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥២.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៦ មាត្រា ៤០ ឬមាត្រា ៤២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ទៅ ១.៥០០.០០០ (មួយលានប្រាំសែន) រៀល និងត់រូវឲ្យមានការធានារ៉ាប់រង ។ ការអនុគ្រោះដែលទាក់ទងក្នុងការអនុវត្តន៍ជាក់ស្តែងនៃវាក្យខ័ណ្ឌខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យដោយអនុលោមទៅតាមប្រភេទយានយន្ត និងប្រភេទការដ្ឋាននីមួយៗ ។

**មាត្រា ៥៣.-**

ការប្រព្រឹត្តិល្មើសនឹងមាត្រា ៤៤ ឬមាត្រា ៤៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ៥០.០០០.០០០ (ហាសិបលាន) រៀល និងត្រូវដកហូតអាជ្ញាប័ណ្ណមកវិញ ។

មាត្រា ៥៤.-

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីដែលជនទាំងនោះនៅតែបន្តប្រព្រឹត្តបទល្មើសដោយពុំរាងចាលនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

មាត្រា ៥៥.-

ចំពោះបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ត្រូវមានការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងណាមួយយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ចំពោះបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដូចមានចែងក្នុងមាត្រា ៣៦ និងមាត្រា ៤២ នៃច្បាប់នេះ ត្រូវមានការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងណាមួយយ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ផុតរយៈពេលកំណត់ទាំងពីរនេះត្រូវអនុវត្តទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

មាត្រា ៥៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

ព្រះហស្តលេខា

នរោត្តម សីហនុ

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

★★★

# ព្រះរាជក្រម នស/រកម/០៧០០/០៣

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឲ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ
# នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ ដូចមានរាយនាមខាងក្រោមនេះ ៖

១-កិច្ចព្រមព្រៀងស្តីពីការជំរុញកិច្ចសហប្រតិបត្តិការលើប្រព័ន្ធផ្សព្វផ្សាយពត៌មាន និងសកម្មភាពវប្បធម៌ធ្វើនៅភ្នំពេញ នាថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៦៩

២-កិច្ចព្រមព្រៀងពហុភាគីស្តីពីសិទ្ធពាណិជ្ជកម្មលើសេវាក្រៅកម្មវិធីរវាងប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ធ្វើនៅម៉ានិល នាថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៧១

៣-កិច្ចព្រមព្រៀងលើការសម្រួលក្នុងការរុករកយន្តហោះក្នុងភាពអាសន្ននិងការសង្គ្រោះជនដែលនៅរស់ក្រោយពីគ្រោះថ្នាក់យន្តហោះ ធ្វើនៅសឹង្ហបុរី ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧២

៤-កិច្ចព្រមព្រៀងលើការសម្រួលក្នុងការរុករកនាវាក្នុងភាពអាសន្ននិងការសង្គ្រោះជនដែលនៅរស់ក្រោយពីគ្រោះថ្នាក់នាវា ធ្វើនៅគូឡាឡាំពួរ នាថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៥

៥-កិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅបាលី នាថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ដែលរួមមានពិធីសារនិងកិច្ចព្រមព្រៀងពាក់ព័ន្ធ ដូចខាងក្រោមនេះ ៖

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅបាងកក នាថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨៣

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅគូឡាឡាំពួរ នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៨៥

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅបាន់ដាសេរីបេហ្គាវ៉ាន់ នាថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៨៩

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅម៉ានិល នាថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩២

៦-កិច្ចព្រមព្រៀងស្តីពីសន្តិសុខស្បៀងបំរុងរបស់អាស៊ាន ធ្វើនៅ ញូវយ៉ក នាថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៩

៧-កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ប័ណ្ណបើកបរក្នុងស្រុកចេញដោយបណ្តាប្រទេសអាស៊ាន ធ្វើនៅគូឡាឡាំពួរ នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៨៥

៨-កិច្ចព្រមព្រៀងស្តីពីការអភិរក្សធម្មជាតិនិងធនធានធម្មជាតិធ្វើនៅគូឡាឡាំពួរ នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៨៥

៩-កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានផ្នែកថាមពលធ្វើនៅម៉ានិល នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

១០-កិច្ចព្រមព្រៀងស្តីពីសន្តិសុខប្រេងឥន្ធនៈអាស៊ាន ធ្វើនៅម៉ានិល នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

១១-កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសដោយអនុគ្រោះលើអ្នកតស៊ូដេញថ្លៃអាស៊ាន សំរាប់ម៉ៅការ ធ្វើនៅហ្សាការតា នាថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៨៦

១២-កិច្ចព្រមព្រៀងអាស៊ានស្តីពីការជំរុញនិងការពារវិនិយោគទុន ធ្វើនៅម៉ានិល នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៨៧ និងពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ធ្វើនៅហ្សាការតា នាថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៦

១៣-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ធ្វើនៅសឹង្ហបុរី នាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩២

១៤-កិច្ចព្រមព្រៀងស្តីពីតារាងអនុគ្រោះពន្ធគយមានប្រសិទ្ធភាពរួម (CEPT) សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅសឹង្ហបុរី នាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩២

១៥-កិច្ចព្រមព្រៀងស្តីពីការបង្កើតមូលនិធិអាស៊ាន ធ្វើនៅបាងកក នាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៤

១៦-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា ធ្វើនៅបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

១៧-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសហប្រតិបត្តិការកម្មសិទ្ធបញ្ញា ធ្វើនៅបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

១៨-កិច្ចព្រមព្រៀងជាមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន ធ្វើនៅសឹង្ហបុរី នាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

១៩-ពិធីសារស្តីពីយន្តការដោះស្រាយវិវាទ ធ្វើនៅម៉ានិល នាថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

២០-កិច្ចព្រមព្រៀងអាស៊ានស្តីពីគយ ធ្វើនៅភូកេត នាថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៧

២១-កិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ាន សំរាប់ថាមពល ធ្វើនៅម៉ានិល នាថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៩

២២-កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់វិញ្ញាបនប័ត្រត្រួតពិនិត្យយានយន្តពាណិជ្ជកម្មសំរាប់ដឹកជញ្ជូន ទំនិញនិងសេវាយានយន្តសាធារណៈ ដែលផ្តល់ដោយបណ្តាប្រទេសអាស៊ាន ធ្វើនៅសឹង្ហបុរី នាថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៨

២៣-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីតំបន់វិនិយោគទុនអាស៊ាន ធ្វើនៅម៉ាកាទី នាថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨

២៤-ពិធីសារស្ដីពីនិតិវិធីនៃការជូនដំណឹង ធ្វើនៅម៉ាកាទី នាថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨

២៥-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសំរបសំរួលក្នុងការទទួលស្គាល់គ្នាទៅវិញទៅមក ធ្វើនៅហាណូយ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨

២៦-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្ដីពីការសំរួលដល់ទំនិញឆ្លងកាត់ ធ្វើនៅហាណូយ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨

២៧-អនុស្សរណៈស្ដីពីការបង្កើតគ្រឹះស្ថានអាស៊ាន ធ្វើនៅគូឡាឡាំពួរ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់ជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈខាងលើនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ ព្រះហស្ថលេខា

សូមឡាយព្រះហស្ថលេខា នរោត្ដម សីហនុ

នាយករដ្ឋមន្ត្រី បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ហត្ថលេខា ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហ៊ុន សែន ហត្ថលេខា

គាត ឈន់

***

ព្រះរាជក្រម នស/រកម/០៧០០/០៨

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរ័ត្ន

និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨

២២ ២៥ ២៦ ២៨ ៣០ ៣៥ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ពលជំពូកទី១៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ច្បាប់
## ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន ដែលធ្វើនៅទីក្រុងប៉េកាំង នាថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តភាប់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា
**ហោ ណាំហុង**

បានយកសេចក្តីបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

**ព្រះរាជក្រម នស/រកម/០៧០០/០៥**

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មអាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងអាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំ អំពីសម្ដេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ប្រកាសឲ្យប្រើ**

ច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ស្ដីពីការជំរុញ និងការពារទៅវិញទៅមកនូវការវិនិយោគ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៧

ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង
ដូចតទៅ :

**ច្បាប់**
**ស្តីពីការអនុម័តយល់ព្រម**
**លើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា**
**និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ដើម្បីជំរុញនិងការពារ**
**ទៅវិញទៅមកនូវការវិនិយោគ**

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ដើម្បីជំរុញនិងការពារទៅវិញទៅមកនូវការវិនិយោគដែលធ្វើនៅភ្នំពេញ នាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តភាពនីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា
នរោត្តម សីហនុ

បានបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

★★★

**ព្រះរាជក្រម នស/រកម/០៧០០/០៦**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីស្តីពី ការជំរុញ និងការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ព្រមស្របតាមលើទំរង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ច្បាប់

## ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋ ឥណ្ឌូនេស៊ីស្តីពីការជំរុញនិងការការពារវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ស្តីពីការជំរុញនិងការការពារវិនិយោគដែលធ្វើនៅហ្សាការតា នាថ្ងៃទី១៦ ខែមិនា ឆ្នាំ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០០

បានបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

ព្រះហស្តលេខា

នរោត្តម សីហនុ

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

★★★

ព្រះរាជក្រម នស/រកម/០៧០០/០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

**ច្បាប់**

**ស្តីពី**

**ការទូទាត់ថវិកាទូទៅរបស់រដ្ឋ**

**សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ។ ការអនុវត្តន៍នេះលេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ :

-ឯកតា : លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយនៃការគ្រប់គ្រង ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ ១៩៩៨ | ច្បាប់ទូទាត់ថវិកា ឆ្នាំ១៩៩៨ |
|---|---|---|
| សរុបចំណូល (១) | ១.៤៥៥.០០០ | ១.៤៥៣.៨៣១ |
| សរុបចំណាយ | ១.៤៥៥.០០០ | ១.៥៦៩.១១០ |
| ចំនួនឱនភាពនៃគណនេយ្យចំណូល/ចំណាយ | | -១១៥.២៧៩ |
| កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុដែលបាន-អនុវត្តដោយធនាគារជាតិ | | |
| ចំណូលថវិកា | | |

| | | |
|---|---|---|
| .ចំណូលក្នុងប្រទេសជាប្រចាំ | ១.០៤៥.០០០ | ៩៩៥.២៨៩ |
| .ចំណូលក្នុងប្រទេសជាមូលធន | ៩១២.០០០ | ៩០៩.៥៦៨ |
| .ចំណូលក្រៅប្រទេសជាមូលធន | ៣៣.០០០ | ៣៣.១៨០ |
| ចំណាយថវិកា | ១០០.០០០ | ១.៥៤១ |
| .ចំណាយជាប្រចាំ | ១.០៤៥.០០០ | ១.០៥៩.៥៦៨ |
| .ចំណាយជាមូលធន | ៨៩៥.០០០ | ៩៣៣.៨៧២ |
| | ១៥០.០០០ | ១២៥.៦៩៦ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| .ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៥០០.០០០ | ៥០៩.៥៤២ |
| .ចំណាយជាមូលធនដោយធនធានសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៥០០.០០០ | ៥០៩.៥៤២ |

---

(១)

ក្នុងនោះមានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះ គ្រាន់ជាការចង្អុលបង្ហាញប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបាន អនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និងមិនបានចុះកិច្ចបញ្ជីការគណនេយ្យក្នុងលេខនាវរតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះគឺគ្រាន់តែ ជាការប៉ាន់ប្រមាណដោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់មូលនិធិ ។

**មាត្រា ២.-**

ចំណូលថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកានៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ១៩៩៨ ត្រូវបានលំអិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះគឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលបានសំរេចក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៨ និងដែលបានបែងចែកតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបានស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ១៩៩៨ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកានិងចំពោះចំណាយត្រូវបាន

លំអិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់នៅក្នុង តារាង “ក ” និង “ខ ” ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង “ខ២” ដែលភ្ជាប់មកជាមួយច្បាប់នេះគឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ក្រៅរតនាគារជាតិដែលបានសំរេចក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៨ និងត្រូវបានបែងចែកតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

## ជំពូកទី ២

## បទប្បញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការថវិកា

**មាត្រា ៣.-**

ការប្រមូលចំណូលជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទានអាករ ផលិតផល និងផលទុនព្រមទាំងការសំរេចបាននូវអំណោយមូលនិធិបរិភាគនិងធនធានដែលបានមកពីការខ្ចី ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ មានចំនួនទឹកប្រាក់សរុប

---------------------------------------- ១.០៤៥.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ -------------------- ៩៤៤.២៨៩ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន ----------------------(-)១០០.៧១១ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ៖

ចំណូលក្នុងប្រទេសជាប្រចាំ -គំរោង ----------------- ៩១២.០០០ លានរៀល

-ការសំរេចបាន ------------- ៩០៩.៥៦៨ លានរៀល

មានចំនួនខ្វះ ---------------(-)២.៤៣២ លានរៀល

ចំណូលក្នុងប្រទេសជាមូលធន-គំរោង ------------------ ៣៣.០០០ លានរៀល

-ការសំរេចបាន -------------- ៣៣.១៨០ លានរៀល

-មានចំនួនលើស ---------------(+)១៨០ លានរៀល

ចំណូលក្រៅប្រទេសជាមូលធន-គំរោង----------------- ១០០.០០០ លានរៀល

-ការសំរេចបាន --------------- ១.៥៤១ លានរៀល

-មានចំនួនខ្វះ ---------------(-)៩៨.៤៥៩ លានរៀល

**មាត្រា ៤.-**

ចំណាយថវិកាទូទៅរបស់រដ្ឋដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ មានចំនួនទឹកប្រាក់សរុប ---------------------- ១.០៤៥.០០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ ------------------- ១.០៥៩.៥៦៨ លានរៀល

ដូច្នេះមានចំណាយលើសឥណទានថវិកាចំនួន ------------(+)១៤.៥៦៨ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ :

ចំណាយជាប្រចាំ -គំរោង ------------------ ៨៩៥.០០០ លានរៀល

-ការសំរេចបាន -------------- ៩៣៣.៨៧២ លានរៀល

-មានចំនួនលើស ------------ (+)៣៨.៨៧២ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-គំរោង ------------------ ១៣៥.០០០ លានរៀល

-ការសំរេចបាន -------------- ១២០.៤២៥ លានរៀល

-មានចំនួនខ្វះ ---------------(-)១៤.៥៧៥ លានរៀល

ចំណាយជាមូលធននៃការរំលស់បំណុល :

-គំរោង ------------------- ១៥.០០០ លានរៀល

-ការសំរេចបាន ---------------- ៥.២៧១ លានរៀល

-មានចំនួនខ្វះ ------------- (+)៩.៧២៩ លានរៀល

## ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទាន
## ក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ
## សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨

មាត្រា ៦.-

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ និងដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ មានចំនួនទឹកប្រាក់ ------------------------------------------------------------៤០០.០០០លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ ------------------------ ៥០៩.៥៤២ លានរៀល

ដូច្នេះមានចំនួនលើស ---------------------- (+)១០៩.៥៤២ លានរៀល

## ជំពូកទី ៤

## បទប្បញ្ញត្តិស្តីពីតុល្យភាពហិរញ្ញវត្ថុសាធារណៈ
## សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨

មាត្រា ៧.-

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថានភាពនៃថវិកាទូទៅរបស់រដ្ឋ បានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការថវិកាដូចតទៅ :

-កិច្ចប្រតិបត្តិការថវិកា : តារាង “ក ” : ចំណូលថវិកាទូទៅរបស់រដ្ឋនិងតារាង “ខ ” : ចំណាយថវិកាទូទៅរបស់រដ្ឋ

-កិច្ចប្រតិបត្តិការនៃរតនាគារជាតិ

-ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋជាមួយនឹងធនាគារជាតិនៃកម្ពុជា

លទ្ធភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចខាងក្រោម :

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+). ឱនភាព(-) |
|---|---|---|
| ១. ចំណូលក្នុងប្រទេស | ៩៤២.៧៥៨ | |
| ១.១- ចំណូលក្នុងប្រទេសជាប្រចាំ | ៩០៩.៥៦៨ | |
| ១.២- ចំណូលក្នុងប្រទេសជាមូលធន | ៣៣.១៩០ | |
| ២. ចំណាយសរុប | ១.៥៦៣.៨៤៣ | |
| ២.១- ចំណាយជាប្រចាំ | ៩៣៣.៨៧២ | |
| ២.២- ចំណាយជាមូលធន (២) | ៦២៩.៩៦៧ | |
| ក្នុងនោះ : | | |
| *វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១២០.៤២៥ | |
| -ដោយមូលនិធិថវិកា | ១០៦.៣៨៩ | |
| .ចំរោងវិនិយោគ (សាងសង់, ទិញសម្ភារៈ) | ៧៣.៦០៩ | |
| .ចំណាយក្នុងប្រទេសលើវិនិយោគដោយហិរញ្ញប្បទានពីបរទេស (គណិភាគ) | ៣២.៧៨០ | |
| -ដោយមូលនិធិបរទេស | ១៤.០៣៦ | |
| *វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ (ជំនួយគំរោងការ) | ៥០៩.៥៤២ | |
| ឱនភាពនៃថវិការជាប្រចាំ (តាមនិយមន័យសន្ទាផ្តល់) | | (-)២៤.៣០៤ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្ទាផ្តល់) | | (-)៦២១.០៨១ |
| ៣. កំណែតំរូវ | | (-)៧.៣៥៩(៣) |
| ឱនភាពនៃថវិការជាប្រចាំ (តាមនិយមន័យបេឡា) | | (-)៣១.៦៦៣ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) | | (-)៦២៨.៤៥០ |
| ៤. ហិរញ្ញប្បទាននៃឱនភាព | | ៦២៨.៤៥០ |
| ៤.១- ហិរញ្ញប្បទានពីបរទេស | | ៥០៥.៤១០ |
| .ជំនួយទ្រទ្រង់ថវិកាមិនមានកំណត់មុខសញ្ញាចំណាយ | | 0 |
| .ជំនួយទ្រទ្រង់ថវិកាមានកំណត់មុខសញ្ញាចំណាយ | | ១.៥២៣ |
| .ជំនួយគំរោងការ | | ៥០៣.៨៨៧(៤) |

| | | |
|---|---|---|
| .ការរំលស់បំណុលបរទេស | | (-)០ |
| ៨.២- ហិរញ្ញប្បទានក្នុងប្រទេស | | (+)១២៣.០៥០ |
| .ហិរញ្ញប្បទានធនាគារជាតិ | | (+)១២០.៣១០ |
| ក្នុងនោះខ្ចីពីធនាគារជាតិ | | ៩២.១៥៨ |
| .ការរំលស់បំណុលក្នុងប្រទេស | | (-)១.៨១៦ |
| .ប្រាក់បញ្ញើនិងកិច្ចប្រតិបត្តិការផ្សេង ៗទៀតនៃរតនាគារ | | ៥.៥៥៦ |

(២) មិនទាន់គិតការរំលស់បំណុល ៥.២៧១ លានរៀលទេ ។

(៣) បំរែបំរួលសុទ្ធនៃអាណត្តិបើកប្រាក់ដែលមាននៅរតនាគារ និង បុរេប្រទានត្រូវធ្វើនិយ័តភាវូបនីយកម្ម ។

(៤) ក្នុងនោះមិនមានទឹកប្រាក់ចំនួន ៥.៦៥៥ លានរៀល ត្រូវរង់ចាំការប្រើប្រាស់ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិស្តីពីនិយតភាវូនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨

**មាត្រា ៨.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ និងមាត្រា ៥៦ នៃច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ និងមាត្រា ២១ នៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ បានអនុម័តជាគោលការណ៍ផ្តល់ឥណទានបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសំរាប់ចំណាយជាប្រចាំនៅក្នុងករណីជាអតិបរមាដូចតទៅ :

-ប្រកាសបន្ថែមចំនួន ២១.០៣៦,៧១ លានរៀល សំរាប់ចំណាយមានលក្ខណៈចាំបាច់នៃបុគ្គលិក ដូចជាប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍សង្គមដែលបានកត់ត្រាទៅលើឥណទានអាចវាយតំលៃបាន (មាត្រា ១៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ។

-អនុក្រឹត្យបុរេប្រទានចំនួន ៧៨.៧៣៩ លានរៀល (មាត្រា៥៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្ថលេខា

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ នរោត្តម សីហនុ

សូមឡាយព្រះហស្ថលេខា បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

នាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា ហត្ថលេខា និងត្រា

ហ៊ុន សែន គាត ឈន់

***

## ២- ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៥

### ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់យល់ព្រះរាជក្រម ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០០

## ប្រកាសបង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ឃ ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាល សំរាប់បណ្តាក្រសួង-ស្ថាប័ននានា ។ ឯការវិវត្តន៍របស់ភ្នាក់ងារម្នាក់ៗគឺស្ថិតនៅក្រោមក្រសួង-ស្ថាប័នសាមី ។

មិនត្រូវបានអនុញ្ញាតឲ្យបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារភ្នាក់ងាររដ្ឋបាលផ្សេងពីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិនៅក្នុងអង្គភាពរដ្ឋបាលកណ្តាលខេត្ត-ក្រុង ហើយនឹងក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។

## ជំពូកទី ២
## ឋានន្តរស័ក្តិនៃក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មាន ៣ ឋានន្តរស័ក្តិ ៖

-នាយភ្នាក់ងាររដ្ឋបាល មាន ០៦ ថ្នាក់
-ភ្នាក់ងាររដ្ឋបាលដើមខ្សែ មាន ១០ ថ្នាក់
-ភ្នាក់ងាររដ្ឋបាល មាន ១៤ ថ្នាក់ ។

## ជំពូកទី ៣
## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ ចំនួនតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៦.-**

ការប្រឡងប្រជែងជ្រើសរើសត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៤
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជនដែលត្រូវបានជ្រើសរើស ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិ មាត្រា ១៦ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីនេះត្រូវបានតាំងស៊ប់ក្នុង ឋានន្តរស័ក្តិ ភ្នាក់ងារ ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សាបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះត្រូវបានលុបឈ្មោះចោល ។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង-ស្ថាប័នសាមីដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ៨.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិមួយរួច [illegible] ររដ្ឋបាលទាំងនេះ ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរមួយ ដែលត្រូវ [illegible] ាមួយឋានន្តរ [illegible] ខ្លួនដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង-ស្ថាប័នសាមីតាមបែបបទដូចបា [illegible] ណត់ក្នុងមាត្រ [illegible] នៃព្រះរាជក្រមចុះ

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ៩.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម :

-គោរពវិន័យការងារបានត្រឹមត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់ឲ្យ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ ក្នុងវេនអតីតភាព ។

**មាត្រា ១០.-**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តឲ្យបានស្របជាមួយចំនួនកំណែងដែលមានទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ដោយរក្សាគោលការណ៍គិតជាភាគរយ :

-ឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល = ៥ ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល = ៧០ ភាគរយ

ការតម្លើងថ្នាក់ និងតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១១.-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ ។

មាត្រា ១២.-

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតំលៃឯកតានៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៣.-

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវដាក់ឲ្យចូលនិវត្តន៍ពេលដល់អាយុ ៥៥ឆ្នាំ ។

ចំពោះការដាក់ឲ្យចូលនិវត្តន៍ សំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

មាត្រា ១៤.-

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ១៥.-

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សូមចុះហត្ថលេខា

ហត្ថលេខា និងត្រា

ពេជ្រ ប៊ុនធិន

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/៣០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **ជាង អេខខួន** បច្ចុប្បន្ន អគ្គលេខាធិការរងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌាបង់ក្លាដែសម៉ូរីស ស្រីលង្កា និង សីហ្សែល ជំនួសឯកឧត្តម **ស៊ឹម ស្ងួន** ដែលត្រូវត្រឡប់ចូលមកក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

មាត្រា ២.- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

តែងតាំង

លោក សេង ឃីសេង

ជា

ឧកញ៉ា

ធ្វើនៅព្រះបរមរាជវាំង ភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៥៧ រស ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

មាត្រា ១.- តែងតាំងឯកឧត្តម បណ្ឌិត អ៊ុក សារ៉ាវុធ ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកលើវិស័យសេដ្ឋកិច្ច និង វិនិយោគ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាចក្រកម្ពុជា លេខ ៧៥៧ រស ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

មាត្រា ១.- តម្លើងឋានៈឯកឧត្តម គាំម កុសល បច្ចុប្បន្ន ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកផ្នែកទំនាក់ទំនងអន្តរជាតិ និងពិធីការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២.- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ,ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

**ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៤០**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៥៧ រស ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

មាត្រា ១.- តម្លើងឋានៈឯកឧត្តម មុំ ខេន បច្ចុប្បន្នជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា និងជានាយកខុទ្ទកាល័យសម្តេច ហេង សំរិន មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២.- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

តែងតាំង

លោក លឹម ហ៊ុយឡេង

ជា

ឧកញ៉ា

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៨២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធ ចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់អនុក្រឹត្យលេខ ៣៧/អនក្រ.តត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង នៃក្រសួងការពារជាតិ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារ និងតម្លើងឋានន្តរសក្តិ ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទ នៃអគ្គបញ្ជាការដ្ឋាន នៃក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម :

**ក- តែងតាំងមុខងារ**

-ឧត្តមសេនីយ៍ទោ **មាស ថន** អត្តលេខ ០០០០៩៤ បច្ចុប្បន្នជា មេបញ្ជាការរង កងទ័ពជើងទឹក

**ខ- តែងតាំងផ្លាស់ប្តូរមុខងារ**

-ឧត្តមសេនីយ៍ត្រី **តាន់ ហារីសនី** អត្តលេខ ០០០១០២ នាយសេនាធិការរង កងអន្តរាគមន៍ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយករង នាយកដ្ឋាន ទាក់ទងអន្តរជាតិ

**គ- តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ**

១- ឧត្តមសេនីយ៍ត្រី **ឡៅ សុខ្ន** អត្តលេខ ០០០២២៩ អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

២- ឧត្តមសេនីយ៍ត្រី **ឌូ ផាន់** អត្តលេខ ០០០២២៨ អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៣- ឧត្តមសេនីយ៍ត្រី **ជាំ ដារ៉ារិទ្ធ** អត្តលេខ ០០០២៩៣ នាយករង ទីចាត់ការឃោសនា និងពត៌មាន បច្ចុប្បន្ន នាយកទីចាត់ការឃោសនា និងពត៌មាន

ឃ- គម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី

-វរសេនីយ៍ឯក ឡោគ ឆាយ អត្តលេខ ០០៣៦១២ ជំនួយការផ្ទាល់ សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋម ន្ត្រីក្រសួងការពារជាតិ
ព្រះហស្តលេខា និង ហត្ថលេខា
អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន ទៀ បាញ់

★★★

## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

**អនុក្រឹត្យលេខ ៤៥ អនក្រ.បក**

**ស្តីពី**

**ការបង្កើតមហាវិទ្យាល័យគ្រប់គ្រងនីតិសាស្ត្រ**

***

**រាជរដ្ឋាភិបាល**

- **បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋម ន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី**

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០1 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា ១.- អនុញ្ញាតឲ្យបង្កើតមហាវិទ្យាល័យឯកជនមួយ ដែលមានឈ្មោះថា មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ **(Faculty of Management and Law)** ហៅកាត់ថា "ម .គ.ន" ។ មហាវិទ្យាល័យនេះ មានទីតាំងនៅ អាគារលេខ ៤៩ស ផ្លូវលេខ ២០៥ សង្កាត់ទួលស្វាយព្រៃទី ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២.- មហាវិទ្យាល័យគ្រប់គ្រង និងនីតិសាស្ត្រ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រដែលមានរយះពេលសិក្សា ៤ឆ្នាំ ។

មាត្រា ៣.- មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ មានមហាវិទ្យាល័យ ពីរ :

-មហាវិទ្យាល័យគ្រប់គ្រង

-មហាវិទ្យាល័យនីតិសាស្ត្រ

ក្នុងពេលអនាគត មហាវិទ្យាល័យនេះ អាចបើកវគ្គបណ្តុះបណ្តាលជំនាញរយះពេលខ្លី និង ជំនាញឯកទេសផ្សេងៗទៀត ក្នុងវិស័យ គ្រប់គ្រង និង នីតិសាស្ត្រ ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៤.- លក្ខខ័ណ្ឌទទួលសិស្សឲ្យចូលរៀន :

-បេក្ខជនទាំងពីរភេទ ជាសិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការ

-បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ

-បេក្ខជនត្រូវឆ្លងកាត់ការប្រលងតេស្ត ។

មាត្រា ៥.- នាយក មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ មានភារកិច្ច :

-ជ្រើសរើស សិស្សឲ្យចូលរៀន និងជ្រើសរើស សាស្ត្រាចារ្យមកបង្រៀន

-គ្រប់គ្រងឲ្យបានល្អ នូវការបង្រៀន ការងារស្រាវជ្រាវ ឯកសារសិក្សា ការប្រលង និងការប្រគល់សញ្ញាប័ត្រ

-គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល

-ធានាឲ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម

-ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និងកីឡា ប្រចាំឆមាសនីមួយៗ ។

មាត្រា ៦.- មហាវិទ្យាល័យនេះមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកក្នុងការគ្រប់គ្រង មហាវិទ្យាល័យ ។

មាត្រា ៧.- នៅក្នុងមហាវិទ្យាល័យនេះ មានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានសមាជិកយ៉ាងតិច ៣នាក់ ដែលមានសញ្ញាប័ត្រម៉ាស្ទ័រយ៉ាងទាប ក្នុងមុខជំនាញ របស់មហាវិទ្យាល័យសំរាប់ពិនិត្យ និង ផ្តល់ការយល់ព្រម លើកម្មវិធីសិក្សា នៅដើមឆ្នាំសិក្សានីមួយៗ ។

មាត្រា ៨.- ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើ អធិការកិច្ច និងត្រួតពិនិត្យ លើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើមហាវិទ្យាល័យនេះ អនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៩.- និស្សិត ដែលរៀនចប់ កម្មវិធីសិក្សា របស់មហាវិទ្យាល័យនេះ និង បានទទួលជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់ឲ្យដោយមហាវិទ្យាល័យគ្រប់គ្រង និងនីតិសាស្ត្រ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ដោយអនុវត្តតាមនិយាមអប្បបរិមា នៃការទទួលស្គាល់គុណភាពបណ្តុះបណ្តាលកំរិតឧត្តមសិក្សា ។

មាត្រា ១០.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងមហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ ត្រូវអនុវត្តភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

មាត្រា ១១.- អនុក្រឹត្យនេះមាន ប្រសិទ្ធភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៨៦ អនក្រ.បក**

**ស្តីពី**

**ការកែប្រែរចនាសម្ព័ន្ធ នៃមហាវិទ្យាល័យ នរ៉ុតុន**

**ទៅជាសកលវិទ្យាល័យ នរ៉ុតុន**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/១០៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការ បង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតមហាវិទ្យាល័យន័រតុន
- តាមសំណើរបស់មហាវិទ្យាល័យ ន័រតុន
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១.- អនុញ្ញាតឲ្យមហាវិទ្យាល័យន័រតុន ដែលមានទីតាំងនៅផ្លូវលេខ ១១៨,១៩ និង ១៣០ សង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កែប្រែឋានសម្ព័ន្ធពីមហាវិទ្យាល័យន័រតុន ឲ្យទៅជា សាកលវិទ្យាល័យ ន័រតុន (NORTON UNIVERSITY) ។

មាត្រា ២.- សាកលវិទ្យាល័យ ន័រតុន មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍របស់ប្រទេស ។

មាត្រា ៣.- ចំពោះមុខ សាកលវិទ្យាល័យ ន័រតុន មានមហាវិទ្យាល័យ ៦ គឺ :

១- មហាវិទ្យាល័យនីតិសាស្ត្រ

២- មហាវិទ្យាល័យសេដ្ឋកិច្ច

៣- មហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងធនធានមនុស្ស

៤- មហាវិទ្យាល័យ វិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វកម្ម

៥- មហាវិទ្យាល័យសណ្ឋាគារ-ទេសចរណ៍

៦- មហាវិទ្យាល័យភាសាអង់គ្លេស និងអប់រំ

សាកលវិទ្យាល័យនេះអាចបើកថ្នាក់ក្រោយឧត្តមសិក្សា -អនុបណ្ឌិត រឺបណ្ឌិត (Master PhD.) មហាវិទ្យាល័យ ផ្នែក រឺ ជំនាញផ្សេងបន្ថែមទៀតតាមតំរូវការសង្គម និង ប្រទេសជាតិ ។

មាត្រា ៤.- លក្ខខ័ណ្ឌទទួលសិស្សឲ្យចូលរៀន :

-សំរាប់ថ្នាក់បរិញ្ញាប័ត្របេក្ខជនទាំងពីរភេទជាសិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

-សំរាប់ថ្នាក់ក្រោយឧត្តមសិក្សា និស្សិតត្រូវមានសញ្ញាប័ត្រ បរិញ្ញាប័ត្រ រឺសមមូល នឹងបរិញ្ញាប័ត្រ ។

មាត្រា ៥.- សាកលវិទ្យាល័យន័រតុន ត្រូវគ្រប់គ្រង និងដឹកនាំដោយក្រុមប្រឹក្សាភិបាល ហើយសាកលវិទ្យាធិការមានភារកិច្ច :

-ជ្រើសរើសបេក្ខជនឲ្យចូលរៀន តាមនិយាមគរុកោសល្យ និង ជ្រើសរើសសាស្ត្រាចារ្យ-បុគ្គលិកសំរាប់ដំណើរការនៃការអប់រំបណ្តុះបណ្តាល ។

-ទទួលខុសត្រូវរួមលើការងារគ្រប់គ្រងផ្នែករដ្ឋបាល និងរៀបចំកែលំអការងារបច្ចេកទេសសិក្សាធិការ ដើម្បីឲ្យសាកលវិទ្យាល័យនេះដំណើរការប្រកបដោយគុណភាព និង ជោគជ័យ ។

-គោរព និង អនុវត្តតាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។

-ធានាឲ្យបាននូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។

មាត្រា ៦.- ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យ លើការងារអប់រំបណ្តុះបណ្តាល ហើយមានសិទ្ធិឲ្យដំបូន្មានដើម្បីលើកកំពស់គុណភាពអប់រំ ។

មាត្រា ៧.- និស្សិតដែលបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការសិក្សា នឹងបានទទួលសញ្ញាប័ត្រថ្នាក់ប្រកាសនីយប័ត្រជាន់ខ្ពស់ សញ្ញាប័ត្រជំនាញជាន់ខ្ពស់ មធ្យមសិក្សាបច្ចេកទេសថ្នាក់បរិញ្ញាប័ត្រ រឺ សញ្ញាប័ត្រថ្នាក់ក្រោយឧត្តមសិក្សា ដែលផ្តល់ឲ្យដោយសាកលវិទ្យាល័យន័រតុន ហើយទទួលស្គាល់ និងចុះហត្ថលេខា ដោយក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៨.- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានឧត្តមសិក្សា អង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាល័យ ន័រតុន មានភារកិច្ចរៀងៗខ្លួនអនុវត្ត និងប្រតិបត្តិការតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

មាត្រា ៩.- រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៩៧ អនក្រ.បក**
**ស្តីពីការផ្ទេរឥណទានថវិកា**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១.-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន ២.៥០០លានរៀល (ពីរពាន់ប្រាំរយលានរៀល) ពីជំពូក៩១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និងការជួសជុលតូច) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

**មាត្រា ២.-** ឥណទានថវិកាក្នុងមាត្រា ១. ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ការចំណាយដំណើរការរដ្ឋបាលសំភារៈ និងការជួសជុលតូច ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៤៨ អនក្រ .បក

## ស្តីពីការផ្ទេរឥណទានថវិកា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១.-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៤០ លានរៀល (សែសិបលានរៀល) ពីជំពូក៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣២

(អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានឲ្យអង្គការអន្តរជាតិនានា) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

មាត្រា ២.- ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ចំណាយបង់វិភាគទានទ្រទ្រង់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នៃប្រទេសទាំង ៤ កម្ពុជា-ឡាវ-ថៃ -វៀតណាម សំរាប់ឆ្នាំ ២០០០ ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ដើម្បីចុះហត្ថលេខា
ហត្ថលេខា
**គាត ឈន់**
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៥៩ អនក្រ .បក
## ស្តីពីការផ្ទេរឥណទានថវិកា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១.- ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន ១.៧០០លានរៀល (មួយពាន់ ប្រាំពីររយលានរៀល) ពីជំពូក ៥០ (ចំណាយផ្សេងៗ ឥណទានបោះឆ្នោតមេឃុំ) នៃខ្ទង់ចំណាយ មិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់រដ្ឋសភា សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

មាត្រា ២.- ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ចំណាយបេសកកម្មរបស់អ្នកតំណាងរាស្ត្រ នៅតាមខេត្តនានា និង តាមពណ្ណលទូទាំងប្រទេស ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្តេចព្រះប្រធានរដ្ឋសភា ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ដើម្បីចុះហត្ថលេខា
ហត្ថលេខា
**គាត ឈន់**
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ២៧០ អនក្រ .តត
## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់មេបញ្ជាការកងពោះតឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់

សំរេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយការងារតាមលំដាប់ថ្នាក់ជូននាយទាហាន នាយទាហានរង កងពោះតឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ និងនាយនគរបាលនាយនគរបាលរង ត្រកូលឆ្មាំព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ចំនួន ៣៧ រូប ដែលមានស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមជូនខាងក្រោម :

ក-មេដាយមាសការងារចំនួន ២៦ រូប :

១- លោកឧត្តមសេនីយ៍ត្រី ពិន ណារិទ្ធ
២- លោកវរសេនីយ៍ឯក សូ ណារ៉ា
៣- លោកវរសេនីយ៍ទោ ឆេត សុគីរី
៤- លោកវរសេនីយ៍ទោ ម៉ុច ឃឿន
៥- លោកវរសេនីយ៍ត្រី ម៉ី ផល្លា
៦- លោកវរសេនីយ៍ត្រី ហង្ស ចាន់ផល្លា
៧- លោកវរសេនីយ៍ត្រី ហ៊ិន រដ្ឋា
៨- លោកវរសេនីយ៍ត្រី ហែម ថេង
៩- លោកវរសេនីយ៍ត្រី កួយ ថា
១០- លោកវរសេនីយ៍ត្រី កែវ ម៉ុនណា
១១- លោកវរសេនីយ៍ត្រី ដួង សុគិនណារ៉ា
១២- លោកវរសេនីយ៍ត្រីប្រាក់ ចាន់ណា
១៣- លោកវរសេនីយ៍ត្រី ចាម សុជា
១៤- លោកវរសេនីយ៍ត្រី សូ សារិទ្ធ
១៥- លោកវរសេនីយ៍ត្រី មាស សឿន
១៦- លោកវរសេនីយ៍ត្រី ឈុន សុវណ្ណារ៉ា
១៧- លោកវរសេនីយ៍ត្រី គង់ បូរ៉ា
១៨- លោកវរសេនីយ៍ត្រី កុយ សារិន
១៩- លោកអនុសេនីយ៍ឯក ដាំ បូរ័ត្ន
២០- លោកអនុសេនីយ៍ឯក អៀង ចាន់ណារិទ្ធ
២១- លោកអនុសេនីយ៍ឯក យឹម រ៉ុង
២២- លោកអនុសេនីយ៍ឯក វង្ស ដារ៉ា
២៣- លោកអនុសេនីយ៍ឯក វង្ស ដារ៉ា
២៤- លោកអនុសេនីយ៍ឯក យស់ សុខុម
២៥- លោកអនុសេនីយ៍ឯក សោម គន្ធា
២៦- លោកអនុសេនីយ៍ត្រី ផូ ត័ត្រា

ខ-មេដាយប្រាក់ការងារ ចំនួន ១១រូប :

១- លោកវរសេនីយ៍ត្រី អ៊ឹម ធូក
២- លោកវរសេនីយ៍ត្រី លុន ផូ
៣- លោកអនុសេនីយ៍ឯក តាន់ សុទិដ្ឋា
៤- លោកអនុសេនីយ៍ឯក ជួន វណ្ណថេត
៥- លោកអនុសេនីយ៍ឯក ឆាយ ម៉ុនណា
៦- លោកអនុសេនីយ៍ឯក គុជ យុន
៧- លោកអនុសេនីយ៍ឯក នុត ចាន់ថារិទ្ធ
៨- លោកអនុសេនីយ៍ឯក សម្បត្តិ មុន្នីរ័ត្ន

៩- លោកអនុសេនីយ៍ទោ យូ សុធារិទ្ធ ១០- អ្នកស្រីអនុសេនីយ៍ទោ យូម៉ូលីខុច

១១- លោកអនុសេនីយ៍ត្រី សុន ចណ្ណៈ

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងមេបញ្ជាការកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៧១ អនក្រ .តត
## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់មេបញ្ជាការកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន

## សម្រេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយការងារតាមលំដាប់ថ្នាក់ជូននាយទាហាន នាយទាហានរង នៃកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន និង អង្គភាពសម្ព័ន្ធមេត្រីភាព ចំនួន ៨៩រូប ដែលមានស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមជូនខាងក្រោម :

**ក-មេដាយមាសការងារចំនួន ៣២ រូប :**

១- លោកវរសេនីយ៍ឯក ឡា ឡៃ ២- លោកវរសេនីយ៍ទោ តូច តារ៉ា

៣- លោកវរសេនីយ៍ទោ រស់ សម្បត្តិ ៤- លោកវរសេនីយ៍ត្រី រស់ សុទ្ធី

៥- លោកវរសេនីយ៍ត្រី ហាយ ម៉ុណ្ណា
៦- លោកវរសេនីយ៍ត្រី ខ្លូត តារា
៧- លោកវរសេនីយ៍ត្រី ហ៊ុយ ទុន្នា
៨- លោកអនុសេនីយ៍ឯក កែវ សំអាន
៩- លោកអនុសេនីយ៍ឯក ចាន់ សំអាន
១០- លោកអនុសេនីយ៍ឯក អ៊ុំ សំអាង
១១- លោកអនុសេនីយ៍ឯក យី នរា
១២- លោកអនុសេនីយ៍ឯក ព្រុំ សំណាង
១៣- លោកអនុសេនីយ៍ឯក ហាក់ សឹងលី
១៤- លោកអនុសេនីយ៍ឯក គឹង ចាន់លី
១៥- លោក ឆោម ភាន
១៦- អ្នកស្រី នាង គឹមម៉ើ
១៧- លោក វិញ ហ៊ិន
១៨- លោក ភង វិគុណ
១៩- លោក យស ណាសី
២០- លោក សូ សារុ
២១- លោក មាន វីភាន់
២២- លោក ព្រុំ សំអ៊ីន
២៣- លោក ខៀវ ហ៊ួន
២៤- លោក តឹម គឹមញ៉ាន
២៥- លោក សុខម៉ុណ្ណា
២៦- លោក អ៊ីវ សារឹក
២៧- លោក កែ ថោងស៊ីន
២៨- អ្នកស្រី យ៉ាន ហុនលី
២៩- លោក អ៊ូ សុផាន
៣០- លោក ផ្លោក ផន
៣១- លោក អ៊ូ សុខជា
៣២- លោក ឡាំង វាសនា

ខ-មេដាយប្រាក់ការងារ ចំនួន ៣៦ រូប :

១- លោកវរសេនីយ៍ត្រី ហែម ថេង
២- លោកអនុសេនីយ៍ឯក ញ៉ែម ស៊ើល
៣- លោកអនុសេនីយ៍ឯក ម៉េងម៉ារ៉ាដា
៤- លោកអនុសេនីយ៍ឯក នៅ ឈុនលី
៥- លោកអនុសេនីយ៍ឯក ពៅ ថៃ
៦- លោកអនុសេនីយ៍ឯក សុខ សាវ៉ាន់
៧- លោកអនុសេនីយ៍ឯក ឆន់ ម៉ុនថន
៨- លោកអនុសេនីយ៍ឯក ម៉ែន ថាច
៩- លោកអនុសេនីយ៍ឯកប្រាក់ ចាន់ថុល
១០- លោក ទឹម វឌ្ឍ
១១- លោក ម៉ឹង នុយ
១២- លោក ជី ស្រី
១៣- លោក នឹងម៉ុម
១៤- លោក នៅ សំបូរ
១៥- លោក យ៉ា ចាន់
១៦- លោក ញ៉ង ហោ
១៧- លោក ម៉ឿង គន្ធ
១៨- លោក មៅ គឿន
១៩- លោក ខួន សឿន
២០- លោក ឯម ថុន
២១- អ្នកស្រី សុខ មុល
២២- លោក ឌុច ភាក់
២៣- លោកនាយចំណង់ ឈាង សុធា
២៤- លោកនាយចំណង់ ឈឿន ឈិន
២៥- លោកនាយចំណង់ គង់ រតនា
២៦- លោកនាយចំណង់ ឆយ កុសល
២៧- លោក អ៊ុំ សុធា
២៨- លោក សុន សឿន
២៩- លោក ឈឹម មន
៣០- លោក រស់ តន

៣១- លោក ណៃ ចាន់ឌី
៣២- លោក សី តៀង
៣៣- លោក នប់ ឈាន់
៣៤- លោក ហ៊ុយ សុខ
៣៥- លោក អ៊ុំ ឡៀង
៣៦- លោក ឈឿន ធូ

គ-មេជាយសិទ្ធការខារ ចំនួន ២០រូប :

១- លោក ជួម សុជាម
២- លោក ខូច សឿន
៣- លោក ស្រី គ្រឿង
៤- លោក ឌីវ ហួន
៥- លោក ឆេ សយ
៦- លោក ប៊ិន សុផាត
៧- លោក ឌិន អ៊ឹម
៨- លោក ម៉ុល ជុស
៩- លោក អ៊ុច គឿ
១០- លោក យូ មិត្ត
១១- លោក ខូច សឿន
១២- លោក ឃន្ស វ៉ៃ
១៣- លោក ទន្ស វ៉ាន់
១៤- លោក ឡោ ហ៊ុយ
១៥- លោក ជុំ សារី
១៦- លោក សាន្ត ផុន
១៧- លោក មាស ចាន់ថុល
១៨- លោក សេក សុត
១៩- លោក ទ្រី ហៀង
២០- លោក ញ៉ែម ញឹម

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងមេបញ្ជាការកងឯកភាពអង្គរក្សសម្តេ ហ៊ុន សែន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានពេទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៧២ អនក្រ .តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- យោងតាមសំណើរបស់ក្រសួងធម្មការ និង សាសនា

**សំរេច**

មាត្រា ១.- តែងតាំងលោក ស្វាយ ហ៊ាង ជាប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងធម្មការនិងសាសនា ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ២៧៣ អនក្រ .តត**
**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោកឧកញ៉ា អ៊ុយ ស៊ើន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងនិងជួសជុល អាគារសិក្សានៅតាមសាលារៀននានា ក្នុងស្រុកបន្ទាយមាសខេត្តកំពត ចំណាយអស់ទឹកប្រាក់ចំនួន ១០៤.៥៩១ដុល្លារអាមេរិក និង ៩៩.៣៦៧.០០០ រៀល ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៧៤ អនក្រ .តត**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឈាង សុធី** អគ្គនាយកក្រុមហ៊ុនជីហ្វូតស្វោតទួកមាស ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង និងជួសជុលអាគារសិក្សា នៅវិទ្យាល័យទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត ចំណាយអស់ទឹកប្រាក់ចំនួន ១៨.០០០ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២៧៥ អនក្រ .តត

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួន ចូលរួមកសាងសមិទ្ធផលនានា ក្នុងវត្ត ពោធិព្រះបាត្រ ហៅវត្តច្បារអំពៅ ក្នុងខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោម :

**ក-មេដាយមាសស្ថាបនាជាតិ :**

១- ព្រះគ្រូ កល្យាណធម្មោ ឈឹម គេត ចៅអធិការវត្តពោធិព្រះបាត្រ ដឹកនាំស្វែងរកថវិកាកសាងវត្ត មានទឹកប្រាក់សរុប ចំនួន ៥៤០.០២០ ដុល្លារអាមេរិក ។

២- លោក សុខ គន់ អភិបាលស្រុកកំរៀង បរិច្ចាគទឹកប្រាក់ ចំនួន ១៥.០០០ ដុល្លារអាមេរិក ។

ខ-មេដាយប្រាក់ស្ហាបនាជាតិ :

១- ឧបាសិកា នៅ ថុល បរិច្ចាគទឹកប្រាក់ចំនួន ៥.៨៥៥ ដុល្លារអាមេរិក

២- ឯកឧត្តម អ៊ី គីហៀង បរិច្ចាគទឹកប្រាក់ចំនួន ៥.៧៥៧ ដុល្លារអាមេរិក

៣- លោក ខូច ជីលី បរិច្ចាគទឹកប្រាក់ចំនួន ៥.០២៥ ដុល្លារអាមេរិក

គ-មេដាយសំរិទ្ធស្ហាបនាជាតិ :

១- ឧបាសក កើត ជា បរិច្ចាគទឹកប្រាក់ចំនួន ៣.៦៣៥ ដុល្លារអាមេរិក

២- លោក គៀង ចាន់ថន បរិច្ចាគទឹកប្រាក់ចំនួន ៣.៥៩៥ ដុល្លារអាមេរិក

៣- លោកគ្រូអាចារ្យ កែវ ប្រាជ្ញ និងគណៈកម្មការវត្តទាំងអស់

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៧៦ អនក្រ .តត**

**ស្តីពីការជូនមេដាយ ស្ហាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ នៃវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនឯកឧត្តម ឌឹង ហួត ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សាមួយខ្នង ក្នុងបរិវេណសាលាបឋមសិក្សា ព្រៃក្រឡា ក្នុងឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ចំណាយអស់ទឹកប្រាក់ចំនួន ២២.០០០ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៧៧ អនក្រ.សស**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោកជំទាវ សាត ណារី ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ១៥.០០០ដុល្លារអាមេរិក សំរាប់សាងសង់អាគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សា ត្រពាំងសាលា ក្នុងឃុំត្រពាំងសាលាខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២៧៨ អនក្រ .តត

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ មេដាយប្រាក់ស្ថាបនាជាតិ ជូនលោក សឹម ស៊ី ជនជាតិខ្មែររស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាត្រពាំងពោន ក្នុងឃុំបន្ទាយមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត ចំណាយអស់ទឹកប្រាក់ ចំនួន ៨.៥០០USD ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ២៧៩ អនក្រ .តត

## ស្តីពីការជូនមេដាយ ស្ហាមនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ហាមនាជាតិ ជូនលោកវរៈសេនីយឯក ម៉ៅ ញ៉ នាយរងអធិការកិច្ចកងទ័ពជើងគោក ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ១៣.០០០ ដុល្លារអាមេរិក សំរាប់ជួយឧត្ថម្ភដល់ ការងារចាំបាច់របស់កងយោធពលខេមរភូមិន្ទ និងជួយជុលអាគារសាលា ស្រុកក្រូចឆ្មារខេត្តក្រចេះ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

អនុក្រឹត្យលេខ ២៨០ អនក្រ .តត
ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ខែលីរ៉ូប៊ីណែត** (Kelly Robinette) នាយកអង្គការ Assemblies of God ដែលបានធ្វើអំណោយជាថវិកា និងកំលាំងចិត្តជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ ដោយបំពាក់សំភារៈសង្ហារិមសិក្សាគ្រប់បន្ទប់ ធ្វើរបងនិងក្លោងទ្វារព្រមទាំងជួយស្ថាបនាសមិទ្ធផលជាច្រើនទៀត នៅក្នុងសាលាបឋមសិក្សាពុកឆ្មារ ភូមិពុកឆ្មារ ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់ចំនួន ៥៣.៣០០ ដុល្លារអាមេរិក ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

អនុក្រឹត្យលេខ ២៨១ អនក្រ .តត
ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សមហេរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនជប៉ុន ០២រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សា នៅសាលាបឋមសិក្សា អន្លង់វិល សាលាបឋមសិក្សា ភូមិខ្សាយ ស្រុកសង្កែ អាគារស្នាក់នៅរបស់កុមារកំព្រា មជ្ឈមណ្ឌលហ្វឹកហ្វឺនវិជ្ជាជីវៈកាត់ដេរនិងជួសជុលពុទ្ធិកវិទ្យាល័យ អ៊ឹម ឆូន ក្នុងខេត្តបាត់ដំបង ដូនមានរាយនាម និងចំនួនទឹកប្រាក់ខាងក្រោមនេះ :

១- លោក តាគស៊ី ហ្វូរីម៉ូតូ ទឹកប្រាក់ចំនួន ៩៥.៦៦៨,៥ ៣USD

២- ព្រះតេជគុណ ឆិជិតាទ៉ា ទឹកប្រាក់ចំនួន ៤៩.៥២១,៥ ៣USD

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៨២ អនក្រ .តត
## ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយសិរីវឌ្ឍនាជាតិ ជូនសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ទិញជាអង្ករចំនួន ៣៤តោន ចែកជូនប្រជាពលរដ្ឋដាច់ស្បៀងចំនួន ៣.៤០០ គ្រួសារ នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដូចមានរាយនាម និងចំនួនទឹកប្រាក់អំណោយខាងក្រោមនេះ ៖

១- ព្រះអង្គម្ចាស់ **ទិវសុចិត្រា ព្រះនាងសីលវតី តេនមុនីទេវី** ទឹកប្រាក់ចំនួន ២.០០០USD

២- ឧបាសិកា **ម៉ែន ខ៊ាម់** ទឹកប្រាក់ចំនួន ២.០០០USD

៣- លោក **ទ្រា ឆាត** ទឹកប្រាក់ចំនួន ២.០០០USD

៤- លោក **ខួត មន្ធុន និងអ្នកស្រី ផា ផន** ទឹកប្រាក់ចំនួន ១.៨០០USD

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ២៨៣ អនក្រ .គត**

**ស្តីពីការជូនមេដាយ ការងារ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាស ការងារ ជាកិច្ចបច្ចាមរណៈ ជូនសពលោក លឹម ស៊ើម អតីត មេឃុំ អូរម៉ាល់ ស្រុកស្វាយពោធិ៍ ខេត្តបាត់ដំបង ជាការរំលឹកដល់ស្នាដៃ និងចារឹកទុកនូវគុណបំណាច់របស់លោក ដែលបានខិតខំបំពេញការងារ សំរេចបានស្នាដៃជាច្រើន ក្នុងការដឹកនាំបង្កបង្កើនផល និងបានស្ថាបនា សមិទ្ធផលសាធារណៈ រួមចំណែកក្នុងការអភិវឌ្ឍន៍ ភូមិ ឃុំ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៨៤ អនក្រ.តត
## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ ជូនសប្បុរសជន ០៥ រូប ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគធនធានជួនកសាងព្រះវិហារវត្តដូងកែវ ក្នុងឃុំកោះតូច ស្រុកកំពត ខេត្តកំពត ដូចមានរាយនាមតាមលំដាប់ថ្នាក់ខាងក្រោម :

**ក-មេដាយមាសស្ថាបនាជាតិ :**

-លោក អ៊ុយ ចន្ទបូ បរិច្ចាគប្រាក់ ១៣.០០០USD

**ខ-មេដាយប្រាក់ ស្ថាបនាជាតិ :**

-លោក សុន សារាយ បរិច្ចាគប្រាក់ ៨.០០០USD

**គ-មេដាយសំរិទ្ធ ស្ថាបនាជាតិ :**

១- លោក ចាន់ សែម បរិច្ចាគប្រាក់ ១.៥០០USD

២- លោក សូ ទ្រី បរិច្ចាគប្រាក់ ១.០០០USD

៣- លោក អ៊ុច គិន បរិច្ចាគប្រាក់ ១.០០០USD

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ២៨៥ អនក្រ .តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៧/អនក្រ.បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើររបស់ក្រសួងសុខាភិបាល

**សំរេច ៖**

មាត្រា ១.- តែងតាំងលោកទន្តបណ្ឌិត សួន ផានី ជាព្រឹទ្ធបុរសមហាវិទ្យាល័យទន្តវេទនសាស្ត្រ នៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៨៦ អនក្រ .តត**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលក្រុងព្រះសីហនុ

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **លឹម ហ៊ុយឡេង** នាយកសណ្ឋាគារ រិត ដែលមានស្នាដៃឆ្នើមក្នុងការចូលរួមស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិ ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសាលារៀន វត្ត លូទឹក ស្ពានច្បារ និងផ្លូវថ្នល់ក្នុងក្រុងព្រះសីហនុ គិតជាទឹកប្រាក់សរុប ចំនួន ២៥២.០០០ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២៨៧ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងសំណូមពរការងារចាំបាច់

**សម្រេច**

មាត្រា ១.- តែងតាំងលោក **ជា អូន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកការងារ អាកាសចរស៊ីវិល មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៨៨ អនក្រ .តត**
**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

មាត្រា ១.- តែងតាំងលោក **ចាន់ សារា** ជានាយក នៃនាយកដ្ឋាននាវាជំនួញសមុទ្រ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២.- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ៨៩ សសរ
### ស្តីពីការបង្កើត
### គណៈកម្មការជាតិពិភាក្សាផ្តល់យោបល់ និង
### ដោះស្រាយបាតុភាពលើការខាតគ្រប់គ្រងតំបន់ការពារធម្មជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល

- បានឃើញសេចក្តីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល
- យោងសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការជាតិអន្តរក្រសួងមួយ ដើម្បីពិភាក្សាផ្តល់យោបល់ និងដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ម៉ុក ម៉ារ៉េត | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តម | គៀង វ៉ាង | រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម | ច័ន្ទ តុងអ៊ីវ | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- ឯកឧត្តម | លី ធុច | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥- ឯ.ឧ.ឧត្តមសេនីយ៍ឯក | ម៉ុល សារឿន | អគ្គមេបញ្ជាការរងនៃបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦- ឯ.ឧ.ឧត្តមសេនីយ៍ឯក | ហុក ឡុងឌី | អគ្គនាយកនគរបាលជាតិ | សមាជិក |
| ៧- ឯ.ឧ.ឧត្តមសេនីយ៍ឯក | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨- ឯកឧត្តម | ស៊ិន សារុន | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- ព្រះអង្គម្ចាស់ | ស៊ីសុវត្ថិ ជីវណ្ណរឹទ្ធី | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០- ឯកឧត្តម | អ៊ុំ ម៉ុនធឿន | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ | សមាជិក |
| ១១- ឯកឧត្តម | កែវ ខេមរា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១២- ឯកឧត្តម អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ | | | សមាជិក |

ប្រការ ២ : គណៈកម្មការជាតិអន្តរក្រសួងនេះ មានភារកិច្ច និងបេសកកម្មដូចតទៅ :

- ចូលរួមពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ចូលរួមពិភាក្សាផ្តល់យោបល់ លើការងារអភិរក្ស និង អភិវឌ្ឍន៍តំបន់ការពារធម្មជាតិ
- លើកវិធានការទប់ស្កាត់ និង ដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យដែលកើតឡើងក្នុងតំបន់ការពារធម្មជាតិ

- ចូលរួមវាយតម្លៃ និង ពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ

ប្រការ ៣ : គណៈកម្មការជាតិអន្តរក្រសួងនេះ ត្រូវបង្កើតអនុគណៈកម្មការចំរុះមួយនៅតាមបណ្តាខេត្ត-ក្រុងពាក់ព័ន្ធដែលមានអភិបាលខេត្តរង ០១រូប ជាប្រធាន ដើម្បីជាជំនួយការសំរាប់បំពេញភារកិច្ចនៅតាមបណ្តាខេត្ត-ក្រុង ដែលមានតំបន់ការពារធម្មជាតិ ។

ប្រការ ៤ : គណៈកម្មការជាតិអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីស្នាក់ការអចិន្ត្រៃយ៍នៅទីស្តីការក្រសួងបរិស្ថាន និង ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

ប្រការ ៥ : សមាជិកគណៈកម្មការជាតិតំណាងឲ្យក្រសួង-ស្ថាប័ន ខេត្ត-ក្រុងនានា និងអនុគណៈកម្មការខេត្ត-ក្រុង ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ២ ខាងលើនិងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការជាតិអន្តរក្រសួង ហើយរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

មាត្រា ៦.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង អនុគណៈកម្មការ និងសមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★